# គោលការណ៍សិទ្ធិមនុស្សនៃ Nissui គ្រុប

Nissui គ្រុប យកចិត្តទុកដាក់ចំពោះការប្រើប្រាស់ធនធានជលផលសមុទ្រប្រកបដោយចីរភាព និងការថែរក្សាបរិស្ថានផែនដី និងបង្កើតគុណតម្លៃចម្រុះពីធនធានធម្មជាតិយ៉ាងសម្បូរបែប ហើយផ្តល់សុខភាពនិងរសជាតិឆ្ងាញ់ជូនដល់ប្រជាជនជុំវិញពិភពលោក។ យើងឃើញថា សិទ្ធិមនុស្សគឺជាអ្វីដែលត្រូវគោរពជាចម្បងក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ទាំងមូលដែលពាក់ព័ន្ធនឹងអាជីវកម្មរបស់យើង ហើយយើងត្រូវខិតខំប្រឹងប្រែងដើម្បីបំពេញភារកិច្ចនោះ។

**ការគោរពសិទ្ធិមនុស្ស**

Nissui គ្រុប គាំទ្រសិទ្ធិមនុស្សដែលមានចែងនៅក្នុង "ធម្មនុញ្ញអន្តរជាតិអំពីសិទ្ធិមនុស្ស" និង "សេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ (ចំណាំ)" និងព្យាយាមអនុវត្តយោងទៅតាម "គោលការណ៍ណែនាំអំពីធុរកិច្ច និងសិទ្ធិមនុស្ស" របស់អង្គការសហប្រជាជាតិ។ លើសពីនេះទៅទៀត ប្រសិនបើមានភាពផ្ទុយគ្នារវាងសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិជាមួយនឹងច្បាប់ក្នុងស្រុកឬក្នុងតំបន់នីមួយៗនោះ យើងនឹងស្វែងរកវិធីសាស្ត្រណាមួយ ដើម្បីការពារនិងគោរពចំពោះគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ។

**វិសាលភាពនៃការអនុវត្ត**

គោលការណ៍នេះត្រូវអនុវត្តចំពោះគ្រប់អ្នកគ្រប់គ្រង និងនិយោជិតដែលស្ថិតនៅក្រោមបណ្តាញរបស់ Nissui Corporation និងក្រុមហ៊ុនក្នុងគ្រុបរបស់ខ្លួន។ យើងក៏ស្នើសុំឱ្យដៃគូអាជីវកម្ម រួមទាំងអ្នកផ្គត់ផ្គង់របស់ Nissui គ្រុប មានការគាំទ្រដល់គោលការណ៍នេះ និងខិតខំគោរពសិទ្ធិមនុស្សផងដែរ។

**ការពិនិត្យដ៏ត្រឹមត្រូវលើសិទ្ធិមនុស្ស**

Nissui គ្រុប កំណត់ហានិភ័យលើសិទ្ធិមនុស្សដែលអាចមានកើតឡើង ឬកំពុងកើតមាន ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយនឹងអភិវឌ្ឍ និងបន្តអនុវត្តប្រព័ន្ធការពារ ឬកាត់បន្ថយហានិភ័យនោះ។

**ការអប់រំ**

Nissui គ្រុប នឹងផ្តល់ការបណ្តុះបណ្តាលនិងអប់រំដល់នាយកនិងនិយោជិតជាប្រចាំ ដើម្បីឱ្យការអនុវត្តគោលការណ៍នេះមានប្រសិទ្ធិភាពស្របតាមសកម្មភាពអាជីវកម្ម។

**ការប្រាស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធ**

Nissui គ្រុប នឹងធ្វើការប្រាស្រ័យទាក់ទ និងពិភាក្សាគ្នាជាមួយនឹងភាគីពាក់ព័ន្ធស្តីអំពីដំណោះស្រាយ ឬវិធីការពារផលប៉ះពាល់ដល់សិទ្ធិមនុស្ស ដែលអាចមានកើតឡើង ឬក៏កំពុងកើតមានឡើងជាក់ស្តែង។

**វិធានការជំនួយ**

ប្រសិនបើឃើញថា Nissui គ្រុប បង្កឱ្យមាន ឬជំរុញឱ្យ មានផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្ស យើងនឹងចាត់វិធានការសមស្របដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**ការបង្ហាញព័ត៌មាន**

Nissui Corporation នឹងបង្ហាញព័ត៌មានអំពីសកម្មភាពគោរពសិទ្ធិមនុស្សតាមគោលការណ៍នេះក្នុងគេហទំព័រក្រុមហ៊ុនយើង។

**ការរៀបចំប្រព័ន្ធគ្រប់គ្រង**
Nissui គ្រុប នឹងកំណត់អ្នកទទួលខុសត្រូវសម្រាប់ការអនុវត្តគោលការណ៍នេះឱ្យបានច្បាស់លាស់ និងរៀបចំស្ថាបនាប្រព័ន្ធគ្រប់គ្រងអាជីវកម្មដើម្បីគោរពសិទ្ធិមនុស្ស។

ធ្វើនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០
(ចំណាំ) ៖ រួមមាន ការហាមឃាត់ការបង្ខំឱ្យធ្វើការ និងការលុបបំបាត់ពលកម្មកុមារ។